**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

**លេខ:០៣៤/០៨ របក.អគគ**

# របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-លិខិតស្នើសុំជួបពិភាក្សា ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រតុលាការគំរូ សម្រាប់តុលាការគំរូខេត្តកណ្តាល នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៨ នៅសាលាដំបូងខេត្តកណ្តាល

-លិខិតស្នើសុំជួបពិភាក្សា ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រតុលាការគំរូ សម្រាប់តុលាការគំរូខេត្តកណ្តាល នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅតុលាការក្រុងភ្នំពេញ

-លិខិតស្នើសុំបញ្ជូនឈ្មោះមន្ត្រីរាជការនៃអង្គភាពគ្រប់គ្រងគម្រោងនៃក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដែលត្រូវតំឡើងបៀវត្សប្រចាំឆ្នាំ២០០៩

-លិខិតស្នើសុំបញ្ជូនឈ្មោះមន្ត្រីរាជការនៃអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដែលត្រូវចូលរួមអបអរសាទរ ថ្ងៃប្រារព្ធខួបលើកទី៣០ នៃទិវាជ័យជំនះ៧ មករា ២០០៩។

### ខ. ការងារកំណែទម្រង់

-បានចូលរួមសិក្ខាសាលាស្តីពី MBPI និង PMG និង SOA នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨

-បានចាប់ផ្តើមអនុវត្តវាយតម្លៃជាបឋម ទាក់ទងទៅនឹងយន្តការ Ombudsman នៅកម្ពុជា ដែលបានជួបជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ

-បានរៀបចំជាទស្សនាទានគម្រោងមូលដ្ឋានទិន្នន័យច្បាប់ នៅក្នុង Website របស់ក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន Serving Web ដើម្បីបង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យច្បាប់បញ្ចូលទៅក្នុង ៊ែបេសិតេ របស់ក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

**គ. ផ្សេងៗ**

-ចូលរួមប្រជុំអន្តរក្រសួង

-បញ្ជូនមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្ស នៅប្រទេសដាណឺម៉ាក ចាប់ពីថ្ងៃទី ២៤ ខែវិច្ឆិកា ដល់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨។

**២-សន្និដ្ឋាន**

ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ ទន្ទឹងនឹងការបន្តសកម្មភាព លើគម្រោងដែលមានស្រាប់ ដូចជាគម្រោងតុលាការគំរូ និងគម្រោងប្រព័ន្ធសូចនាករជាដើម កំពុងតែមានដំណើរការទៅមុខ។ នៅក្នុងខែនេះផងដែរអង្គភាពគ្រប់គ្រងគម្រោង បានរៀបចំទស្សនាទានគម្រោងមូលដ្ឋានទិន្នន័យច្បាប់ នៅក្នុងWebsite របស់ក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ

-រៀបចំឯកសារសម្រាប់ដាក់ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន សម្រាប់ជំនួបជាមួយធនាគារពិភពលោក

-ត្រៀមលក្ខណៈ សម្រាប់ជួបពិភាក្សាជាមួយគណៈប្រតិភូវិទ្យាស្ថានដាណឺម៉ាក់ សម្រាប់សិទ្ធិមនុស្ស (DIHR) ស្តីពីជំនួយឧបត្ថម្ភដល់អង្គភាពគ្រប់គ្រងគម្រោងសម្រាប់ឆ្នាំ២០០៩។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊្វង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង